**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ១៤៩៧ ព.ណ.ឧប.ត

ថ្ងៃ ច័ន្ទ ១១ រោច ខែ បឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០២១

# សេចក្តីជូនដំណឹង
## ស្តីពី
## ការប្រគល់សិទ្ធិជូនអ្នកតំណាង ឬភ្នាក់ងារក្នុងការចុះបញ្ជីពាណិជ្ជកម្ម

ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូន អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី ដែលជាស្ថាបនិក និងពាណិជ្ជករទាំងអស់មេត្តាជ្រាបថា អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី អាចធ្វើការស្នើសុំចុះបញ្ជីពាណិជ្ជកម្មជាទម្រង់សហគ្រាសឯកបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធន បានដោយខ្លួនឯងផ្ទាល់តាមរយៈគេហទំព័រ www.registrationservices.gov.kh ។ ក្នុងករណី អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី ប្រគល់សិទ្ធិឱ្យបុគ្គលជាអ្នកតំណាងក្នុងការចុះបញ្ជីពាណិជ្ជកម្មជាទម្រង់ក្រុមហ៊ុនសហកម្មសិទ្ធិ ឬក្រុមហ៊ុនមូលធន ជំនួសខ្លួន នោះបុគ្គលដែលទទួលសិទ្ធិជាអ្នកតំណាងត្រូវតែជាភ្នាក់ងារចុះបញ្ជីពាណិជ្ជកម្មដែលទទួលស្គាល់ដោយក្រសួងពាណិជ្ជកម្មដូចមានរាយនាមក្នុងបញ្ជីភ្ជាប់ជូន។

ដោយឡែកចំពោះការស្នើសុំចុះបញ្ជីពាណិជ្ជកម្មជាទម្រង់សហគ្រាសឯកបុគ្គល អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី អាចប្រគល់សិទ្ធិជូនបុគ្គលណាមួយក៏បាន។

ក្រសួងពាណិជ្ជកម្ម នឹងអនុវត្តន៍សេចក្តីជូនដំណឹងនេះ ចាប់ពីថ្ងៃទី០២ ខែសីហា ឆ្នាំ២០២១ តទៅ។

អាស្រ័យដូចបានជម្រាបជូនដំណឹងខាងលើ សូម អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី ជ្រាបជាព័ត៌មាន។

សូមអរគុណ!

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469